## ខ ឬប្រការរបស់លោក Martens (Martens Clause:MC)

MC នេះយកតាមឈ្មោះរបស់ប្រតិភូសភាពសូវៀត ដែលអានសេចក្តីថ្លែងការណ៍ នៅឯសន្និសីទសន្តិភាពឡាអេលើកទី១ ឆ្នាំ ១៨៩៩ (first Hague Peace Conference) គឺលោក Fyodorovich Martens។ ខនេះមានន័យថា៖ រហូតដល់ពេលមានក្រមពេញលេញស្តីពីច្បាប់សង្គ្រាម រដ្ឋភាគី យល់ថាវាជាការត្រឹមត្រូវ ក្នុងការប្រកាសថា ក្នុងករណីមិនមានចែងក្នុងបទប្បញ្ញត្តិអនុម័តដោយពួកគេ ប្រជាជន និង សត្រូវបដិបក្ស ទទួលបានការការពារក្រោមគោលការណ៍ច្បាប់អន្តរជាតិ ដែលជាលទ្ធផលពីការប្រើប្រាស់រវាងពួកគេ ពីច្បាប់មនុស្សជាតិ និងពីការទាមទារនៃសតិសម្បជញ្ញៈសាធារណៈ។

ខនេះ ជាដំណោះស្រាយចំពោះជំហរខ្វែងគ្នារវាងក្រុមប្រទេសដឹកមុខដោយប្រទេស បែលសិក ដែលថាចលនាប៉ះបោរប្រដាប់អាវុធ ត្រូវចាត់ថាជាអ្នកប្រយុទ្ធស្របច្បាប់ (legal combatant) និងទទួលឋានៈជាឈ្លើយសឹក (prisoner of war) និងក្រុមមហាអំណាច ដែលថា ពួកគេជាអ្នកប្រយុទ្ធខុសច្បាប់។ ទោះបីជាយ៉ាងនេះក្តី ចលនានេះ មិនត្រូវបានដាក់បញ្ចូលក្នុងអត្ថបទទេ ហើយក្រុមអ្នកស្នើបានប្រកាន់ជំហរបកស្រាយថា កង្វះនៃការដាក់បញ្ចូល មិនអាចត្រូវបកស្រាយថា ជាការដោះស្រាយចប់នូវបញ្ហាទេ។

ខខាងលើ បើកផ្លូវដល់បទប្បញ្ញត្តិក្រោយៗមកទៀត ដែលត្រូវបានដាក់បញ្ចូល។ ជាក់ស្តែង GC III មាត្រា៤(A)2 បានទទួលស្គាល់ចលនានោះ ជាអ្នកប្រយុទ្ធស្របច្បាប់។ បន្ថែមពីលើនេះ វាមានចែងក្នុងអនុសញ្ញាបន្តបន្ទាប់មកទៀត ដូចជា ពិធីសារបន្ថែម ទី១ (OP I)។ មកដល់ពេលនេះ ខនេះ បានក្លាយជាវិធានទំនៀមទម្លាប់អន្តរជាតិ (customary international law) Antonio Cassese, the Oxford Companion to International Criminal Justice, 2009. p.411)។